ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ :.........៣៤.........ប៩.ណក.

ភ្នំពេញ, ថ្ងៃទី២៤ខែមករា ឆ្នាំ ២០០២

# ប្រ ក ា ស

## ស្តីពីការបង្កើតគណៈកម្មការរៀបចំកិច្ចប្រជុំ ស្តីពី ការធ្វើអាជីវកម្មប្រៃសណីយ៍អាស៊ានលើកទី ៩

## ( 9th ASEAN POSTAL BUSINESS MEETING )

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-យោងលិខិតលេខ ១៧១៣ សជណគប ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០០០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញការងារចាំបាច់របស់ក្រសួង

## សំ រេ ច

ប្រការ ១ : ត្រូវបានបង្កើតគណៈកម្មការកណ្តាលមួយរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | រស់ សម័យ | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២-លោក | គុយ ពុំ | នាយកខុទ្ទកាល័យ | អនុប្រធានទី១ |

| | | | |
|---|---|---|---|
| ៣-លោក | ព្រុំ សុន្ថា | អនុប្រធានក្តាប់រួមនាយកដ្ឋានប្រៃសណីយ៍ | អនុប្រធានទី២ |
| ៤-លោក | កែវ វុឌ្ឍិន | អនុប្រធាននាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ | សមាជិក |
| ៥-លោក | ព្រាប សុរិទ្ធី | អនុប្រធាននាយកដ្ឋានប្រៃសណីយ៍ | សមាជិក |
| ៦-លោក | អៀង ស្រេង | អនុប្រធាននាយកដ្ឋានប្រៃសណីយ៍ | សមាជិក |
| ៧-លោក | ឈី សុខា | អនុប្រធាននាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ | សមាជិក |
| ៨-លោក | ប៉ុក សូផាត | ប្រធានការិយាល័យរដ្ឋបាល នៃខុទ្ទកាល័យ | សមាជិក |
| ៩-អ្នកស្រី | លឹប លឿង | ប្រធានការិយាល័យហិរញ្ញវត្ថុ នៃនាយកដ្ឋានប្រៃសណីយ៍ | សមាជិក |
| ១០-លោក | វង្ស ស៊ុម | ប្រធានការិយាល័យរដ្ឋបាល នៃនាយកដ្ឋានប្រៃសណីយ៍ | សមាជិក |
| ១១-លោក | អាំ សំអាត | ប្រធានមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តសៀមរាប | សមាជិក |

ប្រការ ២ : គណៈកម្មការកណ្តាល មានភារៈកិច្ចដឹកនាំរួមក្នុងការរៀបចំកិច្ចប្រជុំ ស្តីពីការធ្វើអាជីវកម្មប្រៃសណីយ៍អាស៊ាន លើកទី ៩ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ០៩ ដល់ថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០០២ នៅទីរួមខេត្តសៀមរាប។

ប្រការ ៣ : គណៈកម្មការកណ្តាលនេះអាចបង្កើតអនុគណៈកម្មការជំនាញក្នុងករណីចាំបាច់ណាមួយ ហើយសមាជិកគណៈកម្មការកណ្តាលទាំងអស់ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ ឯកឧត្តមប្រធាន ។ នៅពេលចប់ភារៈកិច្ចត្រូវរាយការណ៍ពីលទ្ធផលនៃ កិច្ចប្រជុំ ជូន ឯកឧត្តមរដ្ឋមន្ត្រី ដើម្បីពិនិត្យ និង សំរេច ។

ប្រការ ៤ : រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារ នៃ ប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : ខុទ្ទកាល័យ-អធិការដ្ឋាន-នាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ-នាយកដ្ឋានប្រៃសណីយ៍-មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តសៀមរាប និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តន៍តាមខ្លឹមសារ នៃប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

សូ ខុន

**កន្លែងទទួល**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- សាលាខេត្តសៀមរាប

  " ដើម្បីជូនជ្រាប "

- ដូចប្រការ ៥ " ដើម្បីអនុវត្តន៍ "
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ